គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
លេខាធិការដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ១៥៥...៧...ស..../គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ ៣ ឆ្នាំ២០១៧

**គោរពជូន**

**ឯកឧត្តម យក់ ប៊ុនណា រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ**
**និងជាអនុប្រធានប្រចាំការនៃគណៈកម្មាធិការកំណែទម្រង់រដ្ឋបាលសាធារណៈ**

**កម្មវត្ថុ** ៖ កិច្ចប្រជុំរវាងលេខាធិការដ្ឋាននៃកម្មវិធីកំណែទម្រង់ទាំង៣។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម** មេត្តាជ្រាបថា ផ្អែកតាមចំណារឯកភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចតេជោ នាយករដ្ឋមន្ត្រី** ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១៧ លើលិខិតរបស់ គ.ជ.អ.ប លេខ០០៩លស/គ.ជ.អ.ប. ចុះថ្ងៃទី១ ខែកុម្ភៈឆ្នាំ២០១៧ ស្តីពីសំណើសុំការពិនិត្យ សម្រេច និងផ្តល់គោលការណ៍តម្រង់ទិសលើកិច្ចការសំខាន់ៗពាក់ព័ន្ធនឹងការជំរុញកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងអនុលោមអនុសាសន៍របស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ក្នុងពិធីបិទសន្និបាតបូកសរុបការងាររបស់ក្រសួងមហាផ្ទៃ នាថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៧ លេខាធិការដ្ឋាន គ.ជ.អ.ប បានផ្តួចផ្តើមសិក្សាជាបឋមអំពីជម្រើសមួយចំនួនសម្រាប់ការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីធ្វើសមាហរណកម្មការិយាល័យជំនាញនានាទៅក្នុងរចនាសម្ព័ន្ធនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌទាំងនោះ។

ដើម្បីជានាឱ្យការគិតគូរ ពិចារណាលើការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ខណ្ឌនេះមានលក្ខណៈគ្រប់ជ្រុងជ្រោយ លេខាធិការដ្ឋាន គ.ជ.អ.ប គ្រោងរៀបចំកិច្ចប្រជុំរវាងលេខាធិការដ្ឋាននៃកម្មវិធីកំណែទម្រង់ទាំង៣ **នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៧ វេលាម៉ោង៨:៣០នាទីព្រឹក នៅសាលប្រជុំលេខាធិការដ្ឋាន គ.ជ.អ.ប** ដែលមានរបៀបវារៈដូចខាងក្រោម៖

- **ការពិភាក្សាលើជម្រើសនានាក្នុងការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ខណ្ឌ។**

ក្នុងករណីដែល**ឯកឧត្តម**យល់ថា មានរបៀបវារៈចាំបាច់ផ្សេងទៀតដែលត្រូវលើកយកមកពិភាក្សាក្នុងកិច្ចប្រជុំនេះ សូម**ឯកឧត្តម**មេត្តាជូនព័ត៌មានមកលេខាធិការដ្ឋាន គ.ជ.អ.ប ឱ្យបានមុនថ្ងៃប្រជុំ។

**ឯកឧត្តម សក់ សេដ្ឋា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប នឹងដឹកនាំសម្របសម្រួលកិច្ចប្រជុំនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម** និង**សហការី** មេត្តាអញ្ជើញចូលរួមកិច្ចប្រជុំរវាងលេខាធិការដ្ឋាននៃកម្មវិធីកំណែទម្រង់ទាំង៣នេះតាមការគួរ។

សូម **ឯកឧត្តម** ទទួលនូវការគោរពដោយស្មោះស្ម័គ្រពីខ្ញុំ។

**អនុប្រធានប្រតិបត្តិ**

ចាន់ [illegible]